ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚ ✻ ៚

ក្រសួងសុខាភិបាល

លេខ ០១១ អបស/ម.ក

រាជធានីភ្នំពេញ ថ្ងៃទី៣ខែ ៦ ឆ្នាំ២០០៤

# ប្រកាស

## ស្តីពី

## កែសម្រួលប្រការ២៤នៃប្រកាសលេខ០២១ អបសមក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៣ របស់ក្រសួងសុខាភិបាល ស្តីពីបែបបទនិងល័ក្ខខ័ណ្ឌបច្ចេកទេស ក្នុងការសុំបើកឬបិទ ពង្រីក ទ្រង់ទ្រាយ ឬប្តូរទីតាំង នៃសេវាវេជ្ជសាស្ត្រ-អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន

៚៚៚៚✻៚៚៚

## ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញ: រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ: ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ: ព្រះរាជក្រមលេខ នស/រក/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញ: ព្រះរាជក្រមលេខ នសរកម/១១០០/១០ ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០០ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការ ប្រកបវិជ្ជាជីវៈឯកជន លើវិស័យវេជ្ជសាស្ត្រ-អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ

-បានឃើញ: ព្រះរាជក្រឹត្យលេខ នស/រកត/០២០០/០៣៩ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈគ្រូពេទ្យ

-បានឃើញ: អនុក្រឹត្យលេខ៦៧ អនក្របក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញ: អនុក្រឹត្យលេខ៥៨ អនក្របក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីបែបបទនិងល័ក្ខខ័ណ្ឌនៃការអនុញ្ញាតឱ្យជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា

-បានឃើញ: ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១-១០-១៩៩៤

-និងយោង: តាមការចាំបាច់របស់ក្រសួងសុខាភិបាល ។

## សំរេច

**ប្រការ ១.-**

ខ្លឹមសារប្រការ២៤នៃប្រកាសលេខ០២១ អបស/មក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៣ របស់ក្រសួងសុខាភិបាល ត្រូវបានកែសំរួលដូចខាងក្រោម ។

**ប្រការ ២៤ថ្មី.-**

-ការផ្តល់លិខិតអនុញ្ញាតច្បាប់ជូនដល់បន្ទប់ពិគ្រោះព្យាបាលជម្ងឺ បន្ទប់ពិគ្រោះព្យាបាលជម្ងឺមាត់-ធ្មេញ បន្ទប់ព្យាបាលដោយចលនា បន្ទប់ថែទាំជម្ងឺ និងបន្ទប់សោភ័ណសល្យសាស្ត្រ ដោយមានបំពាក់ជូនផ្លាកសញ្ញា Logo ជាសំគាល់ ព្រមទាំងមានចុះលេខបញ្ជីការពីមន្ទីរសុខាភិបាលខេត្ត-ក្រុង គឺផ្តល់ជូនច្បាប់អនុញ្ញាតរយៈពេល ៣ឆ្នាំ ម្តង ។

ទីស្តីការក្រសួងសុខាភិបាល, លេខ ១៥១-១៥៣ វិថី កម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៤២៦ ០៧៤/៤២៦ ៨៤១ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៨៧៣

-ការផ្ដល់លិខិតអនុញ្ញាតច្បាប់ជូនដល់មន្ទីរពិសោធន៍-មន្ទីរសម្ភព-មន្ទីរសំរាកព្យាបាល-មន្ទីរព្យាបាលមាត់ធ្មេញ និងមន្ទីរពហុព្យាបាល ដោយមានបំពាក់ជូនផ្លាកសញ្ញាសំគាល់ Logo ដែលមានចុះលេខបញ្ជីការពីក្រសួងសុខាភិបាល គឺផ្ដល់ច្បាប់អនុញ្ញាតជូនរយៈពេល ៤ឆ្នាំ ម្ដងក្នុងករណីវេជ្ជបណ្ឌិត ឬឱសថការី ឬទន្តបណ្ឌិត ដែលឈរឈ្មោះជាអ្នកគ្រប់គ្រងនោះចូលនិវត្តន៍ ឬបោះបង់ឈប់ពីការងាររដ្ឋ ។ ដោយឡែកមន្ត្រីដែលកំពុងបំរើការងាររដ្ឋ ហើយបានសុំផ្អាកការងារមិនយកបៀវត្សន៍មកឈរឈ្មោះជាអ្នកគ្រប់គ្រង នោះក្រសួងសុខាភិបាល និងផ្ដល់ច្បាប់អនុញ្ញាតជូនទៅតាមរយៈពេលនៃការសុំផ្អាកការងារមិនយកបៀវត្សន៍ ។

ផុតកំណត់កាលបរិច្ឆេទ អ្នកគ្រប់គ្រងសេវាឯកជនទាំងអស់ ត្រូវសុំច្បាប់អនុញ្ញាតិបន្តសារជាថ្មីឡើងវិញ ឬត្រូវសុំប្ដូរអ្នកឈរឈ្មោះគ្រប់គ្រង ។

**ប្រការ ២.-**

អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋានក្រសួងសុខាភិបាល នាយកដ្ឋានមន្ទីរពេទ្យ និងមន្ទីរសុខាភិបាលខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋ. ហុង - ស៊ុនហួត

<u>ចំលងជូន</u>

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា-រដ្ឋសភា
-ទិស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងយុត្តិធម៌
-ក្រសួងមហាផ្ទៃ
-គណៈគ្រពេទ្យថ្នាក់ជាតិនិងខេត្ត-ក្រុង
-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-អគ្គាធិការដ្ឋានក្រសួងសុខាភិបាល
-សាលាក្រុងភ្នំពេញ និងខេត្ត-ក្រុង
-នាយកដ្ឋានមន្ទីរពេទ្យ
-មន្ទីរសុខាភិបាលខេត្ត-ក្រុង
-មជ្ឈមណ្ឌលនិងមន្ទីរពេទ្យជាតិ
-ឯកសារ កាលប្បវត្តិ